ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា

លេខ: ១៨ សកបយ

ភ្នំពេញ ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ ២០០១

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានកិត្តិយសសូមជំរាបជូនដល់ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ថា យោងតាមសំណូមពររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមលិខិតលេខ ០៧.៣៩៨/០១ គជប ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០១ លោកនាយក ឬម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវសម្រួលអោយកម្មករ និយោជិតបានទៅចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០១ ដល់ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០១ ទៅតាមលក្ខណៈជាក់ស្តែងនៃអាសយដ្ឋានពិតប្រាកដនិងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោតដូចខាងក្រោម:

-ចំពោះកម្មករ និយោជិត ដែលមានអាសយដ្ឋានក្នុងរាជធានីភ្នំពេញ ហើយការិយាល័យចុះឈ្មោះនៅជិតៗទីតាំងរោងចក្រ សហគ្រាសនោះ និយោជកត្រូវអនុញ្ញាតច្បាប់ទៅចុះឈ្មោះដោយប្តូរវេនគ្នា ឬជាក្រុមៗទៅចុះឈ្មោះ។ *អវត្តមានពីការងាររបស់កម្មករ និយោជិត សំរាប់ការទៅចុះឈ្មោះបោះឆ្នោតនេះត្រូវចាត់ទុកដូចជាកម្មករ និយោជិត បានធ្វើការ ធម្មតា។*

-ចំពោះកម្មករ និយោជិត ដែលមានអាសយដ្ឋានឆ្ងាយឬមានអាសយដ្ឋាននៅតាមខេត្ត-ក្រុងផ្សេងៗ និយោជកត្រូវអនុញ្ញាតច្បាប់អោយទៅចុះឈ្មោះតាមតារាងខាងក្រោមនេះ។ *ការអនុញ្ញាតច្បាប់នេះត្រូវចាត់ទុកជាការអនុញ្ញាតច្បាប់ឈប់សំរាកពិសេសរបស់ កម្មករ និយោជិត។*

តារាងសំរាប់ការអនុញ្ញាតច្បាប់ជូនកម្មករ និយោជិត

ទៅចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ_សង្កាត់

| ល.រ | ទីតាំងរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន | ចំនួនថ្ងៃដែលត្រូវអនុញ្ញាតច្បាប់ | ផ្សេងៗ |
|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ពីកន្លះថ្ងៃ ទៅមួយថ្ងៃ | |
| ២ | ពីរាជធានីភ្នំពេញទៅខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង | ពីរថ្ងៃ | |
| ៣ | ពីរាជធានីភ្នំពេញទៅ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តព្រៃវែង ខេត្តកំពង់ធំ ខេត្តស្វាយរៀង ខេត្តកំពត ខេត្ត | បីថ្ងៃ | |

| | | | |
|---|---|---|---|
| | សៀមរាប ខេត្តតាកែវ និងក្រុងព្រះសីហនុ | | |
| ៤ | ពីរាជធានីភ្នំពេញទៅ ខេត្ត-ក្រុងដទៃទៀតក្រៅពីខេត្ត-ក្រុងទាំងអស់ខាងលើ | បួនថ្ងៃ | |

ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថានដែលមានទីតាំងនៅតាមខេត្ត-ក្រុងដទៃទៀតក្រៅពីរាជធានីភ្នំពេញ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករ និយោជិតទៅចុះឈ្មោះតាមចំនួនថ្ងៃដូចមានចែងក្នុងតារាងខាងលើដែរ ដោយយកខេត្ត-ក្រុងនីមួយៗធ្វើជាមូលដ្ឋានដើមដូចគ្នានឹងរាជធានីភ្នំពេញដែរ ។ ឧទាហរណ៍: កម្មករ និយោជិតធ្វើការនៅរោងចក្រ សហគ្រាសនៅក្នុងក្រុងព្រះសីហនុ ហើយត្រូវចុះឈ្មោះបោះឆ្នោតនៅក្រុងព្រះសីហនុ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករ និយោជិត ពីកន្លះថ្ងៃទៅមួយថ្ងៃ ។ ប៉ុន្តែបើកម្មករ និយោជិតត្រូវទៅចុះឈ្មោះបោះឆ្នោតនៅភ្នំពេញ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករ និយោជិត ចំនួន បីថ្ងៃ ។

ចំពោះកម្មករ និយោជិតដែលអវត្តមានហួសពីច្បាប់អនុញ្ញាតដូចមានចែងខាងលើ ត្រូវទទួលខុសត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាស ។

ក្រសួងមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោកជាម្ចាស់ និងនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព ប្រកបដោយការយោគយល់ជាពុំខាន ។

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

ចម្លងជូន:
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីជូនជ្រាប
- គ្រប់ក្រសួងពាក់ព័ន្ធ ដើម្បីជូនជ្រាប
- អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្សព្វផ្សាយ និងអនុវត្ត
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង ដើម្បីជូនជ្រាប
- សម្ព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) ដើម្បីអនុវត្ត
- គ្រប់សហជីពសមាជិក ដើម្បីជ្រាប
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ ដើម្បីជួយផ្សព្វផ្សាយ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ